កម្មវិធីសិក្សានៅផ្ទះ Home Learning Opportunities នឹងចាប់ផ្តើមតាមអនឡាញនៅថ្ងៃនេះ

ដូចដែលបានជូនដំណឹងកាលពីសប្តាហ៍មុនមក ការបិទសាលាទាំងអស់នៅក្នុងក្រសួងអប់រំឡុងប៊ីច LBUSD នឹងពន្យារបន្តរហូតដល់ថ្ងៃទី៣ខែឧសភាយ៉ាងឆាប់ ដោយសារស្ថានភាពវីរុសកូរ៉ូណា។ នៅល្ងាចថ្ងៃនេះ LBUSD នឹងចាប់ផ្តើមផ្តល់កម្មវិធីសិក្សានៅផ្ទះ សំរាប់ការសិក្សាទូទៅ  និងសិស្សក្នុងកម្មវិធីអប់រំពិសេសហើយនិងក្រុមគ្រួសារសិស្ស។  កម្មវិធីសិក្សានៅផ្ទះនេះគឺសម្រាប់ក្នុងកំឡុងរយៈពេលពីថ្ងៃច័ន្ទ ទី២៣មិនា ទៅដល់ថ្ងៃព្រហស្បតិ៍ ទី៩មេសា។ មេរៀននិងធនធានសិក្សាត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់កម្មវិធីការសិក្សាជាបន្ត នៅក្នុងកំរិតថ្នាក់របស់សិស្ស រហូតដល់ថ្ងៃទី៩មេសា (ដែលគឺជាថ្ងៃមុនថ្ងៃបុណ្យឈប់សម្រាកនៅថ្ងៃទី១០មេសា និងការឈប់សម្រាកនិទាឃរដូវមួយសប្តាហ៍ក្នុងសប្តាហ៍បន្ទាប់)។ កម្មវិធីសិក្សានៅផ្ទះនេះនឹងមិនមានកត់ជាពិន្ទុទេ។

នៅក្នុងកំឡុងពេលដែលសាលាបិទទ្វារនេះ សិស្សនិងមាតាបិតាអាចប្រើគេហទំព័រឱកាសនៃការសិក្សានៅផ្ទះដើម្បីរកមើលធនធានកម្មវិធីសិក្សាសម្រាប់សាលារៀននីមួយៗ។ គេហទំព័រនេះអាចចូលតាមរយៈ

- បណ្តាញបន្តភ្ជាប់នឹងកម្មវិធីសិក្សានៅផ្ទះ Home Learning Opportunities នៅលើទំព័រដើមនៃ lbschools.net
- បណ្តាញបន្តភ្ជាប់នឹងកម្មវិធីសិក្សានៅផ្ទះ Home Learning Opportunities នៅលើទំព័រដើមនៃគេហទំព័រសាលារៀននីមួយៗ
- ដោយផ្ទាល់នៅ lbschools.net/HLO

ចំពោះសិស្សដែលត្រូវការកុំព្យូទ័រ ក្រូមប៊ុគ Chromebook ឧបករណ៍នេះនឹងមានឱ្យប្រើចាប់ពីថ្ងៃពុធទី២៥មិនាទៅ។ សាលារៀនក៏អាចផ្តល់ព័ត៌មានអំពីការមានលទ្ធភាពប្រើប្រាសអ៊ិនធើនែតនៅផ្ទះផងដែរ ចំពោះគ្រួសារណាដែលមិនមានអ៊ិនធើនែតនៅផ្ទះ។ សម្ភារៈសិក្សានៅផ្ទះនឹងមានផ្តល់ជាក្រដាសដល់គ្រួសារណាដែលត្រូវការ ចាប់ផ្តើមនៅថ្ងៃអង្គារ ទី២៤មិនា នៅតាមសាលារៀនដែលមានចែកអាហារ។